# ប្រវត្តិសាស្ត្រសង្ខេបនៃសហរដ្ឋអាមេរិក ទំនាក់ -ទំនងរដ្ឋហាវ៉ៃ

**ឆ្នាំ ១៨២៦** - សហរដ្ឋអាមេរិកបានទទួលស្គាល់ព្រះរាជាណាចក្រហាវ៉ៃថាជាប្រទេសឯករាជ្យ និងមានអធិបតេយ្យភាព ។

**ឆ្នាំ ១៨៩៣** - កងទ័ពជើងទឹករបស់សហរដ្ឋអាមេរិកបានកាន់កាប់ហាវ៉ៃ ដោយយកផលប្រយោជន៍សន្តិសុខរបស់សហរដ្ឋអាមេរិកធ្វើជាលេស ហើយរដ្ឋមន្ត្រីសហរដ្ឋអាមេរិក បានដោតទង់ជាតិរបស់អាមេរិកនៅលើទឹកដីហាវ៉ៃ ដោយប្រកាសថា ហាវ៉ៃ គឺជាដែនដីស្ថិតក្រោមអាណាព្យាបាលរបស់សហរដ្ឋអាមេរិក។ បន្ទាប់មក រដ្ឋាភិបាលសហរដ្ឋអាមេរិក "ធ្វើឱ្យ" មហាក្សត្រិយហាវ៉ៃ ព្រះនាម Liliuokalani ចុះចេញពីការគ្រោងរាជ ។ (សូមអានការតវ៉ារបស់មហាក្សត្រិយតាមរយៈគេហទំព័រ http://www.kanakamaolipower.org/history.php) ។

**ឆ្នាំ ១៨៩៨** - សហរដ្ឋអាមេរិកបានដាក់ហាវ៉ៃជាដែនដីឧបសម្ពន្ធរបស់ខ្លួន "ជាផ្លូវការ" ដោយមិនបានឆ្លងកាត់បទដ្ឋាននានា មានដូចជាសន្ធិសញ្ញាឧបសម្ពន្ធជាដើមខណៈពេលដែលសន្ធិសញ្ញាបែបនេះ តែងតែត្រូវបានព្រមព្រៀងបញ្ចប់ជាមុនសិន នៅពេលដាក់ដែនដី Louisiana, Florida, Texas និងដែនដីផ្សេង ទៀតជាឧបសម្ពន្ធ។ តាមច្បាប់អន្តរជាតិ អវត្តមាននៃសន្ធិសញ្ញាឧបសម្ពន្ធ មានន័យថា អធិបតេយ្យភាពនៃប្រទេសដែលត្រូវបានបញ្ចូលជាឧបសម្ពន្ធនោះ នៅមាននៅឡើយ មិនទាន់បាត់បង់ទេ។

**ឆ្នាំ ១៩៥៩** - សហរដ្ឋអាមេរិកបានរៀបចំធ្វើការបោះឆ្នោតប្រជាមតិ ដើម្បីសួរប្រជាជនហាវ៉ៃ ថាតើពួកគេចង់រក្សាស្ថានភាពអាណាព្យាបាលរបស់ខ្លួន ឬចង់ចូលរួមក្នុងសហរដ្ឋអាមេរិកក្នុងនាមជារដ្ឋមួយ។ ដើម្បីទទួលបានលទ្ធផលស្របទៅនឹងផលប្រយោជន៍របស់ខ្លួន សហរដ្ឋអាមេរិកបានលប់ចោលសំណួរទីបីដែលមានចែងនៅក្នុងធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ អំពីថាតើប្រជាជនហាវ៉ៃចង់បានឯករាជ្យភាពដែរ ឬអត់។ ដោយមានជំនួយពីការបោះឆ្នោតគាំទ្របន្ថែមពីយោធាអាមេរិកចំនួន ១០.០០០ នាក់ ដែលកំពុងឈរជើងនៅក្នុងព្រះរាជាណាចក្រហាវ៉ៃ ពួកគេបានទទួលសំឡេងឆ្នោតភាគច្រើនសម្រាប់ការចូលរួមជាមួយសហរដ្ឋអាមេរិក ហើយបន្ទាប់មកហាវ៉ៃ ត្រូវបានរួមបញ្ចូលជា រដ្ឋទី៥០របស់សហរដ្ឋអាមេរិក។

**បច្ចុប្បន្ន** - ហាវ៉ៃ គឺនៅតែជាដែនដីអាណានិគមដ៏ស្រស់ស្អាតបំផុតនៃអាណាចក្រអាមេរិក ហើយសហរដ្ឋអាមេរិកនៅតែបន្តគ្រប់គ្រងជនជាតិហាវ៉ៃដែលកំពុងស្វែងរកឯករាជ្យភាព តែជាប់គាំងងាកខ្លួនមិនរួច។ ប៉ុន្តែ ថាតើស្ថានភាពនេះនឹងបន្តរយៈពេលយូរប៉ុនណាទៀត?

គួរឱ្យសោកស្តាយ នាពេលបច្ចុប្បន្ន ជនជាតិអាមេរិកបន្តក្រើនរលឹកគ្រប់ទីកន្លែងថា ៖ "*យើងជាប្រជាជាតិដ៏អស្ចារ្យបំផុតនៅលើភពផែនដីនេះ* "! និងអ្វីៗដែលពលរដ្ឋអាមេរិកបង្រៀនសិស្សសាលាឱ្យសច្ចាប្រណិធាននៅពេលធ្វើការប្តេជ្ញាចិត្ត? *"... ជាមួយសេរីភាព និងយុត្តិធម៌សម្រាប់ទាំងអស់គ្នា"!*

*ដើម្បីស្វែងយល់បន្ថែមអំពីចលនាទាមទារឯករាជ្យភាពរបស់ជនជាតិហាវ៉ៃ សូមចូលមើលគេហទំព័រ* [www.kanakamaolipower.org](http://www.kanakamaolipower.org) *និង* [www.thelawfulhawaiiangovernment.org](http://www.thelawfulhawaiiangovernment.org)

បន្ទាប់ពីការបះបោរក្នុងខែមករា ឆ្នាំ១៨៩៣ មហាក្សត្រិយ Liliuokalani ដែលជាក្សត្រអាស្រ័យរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រហាវ៉ៃ បានផ្ញើព្រះរាជសារតវ៉ាដូចខាងក្រោម ជូនទៅប្រធានាធិបតីសហរដ្ឋអាមេរិក Grover Cleveland ដើម្បីទាមទារឱ្យមានការដកកងទ័ពជើងទឹករបស់សហរដ្ឋអាមេរិក ដែលជួយក្រុមជនសមគំនិតនៅក្នុងការធ្វើរដ្ឋប្រហារ។ ការបញ្ជូនព្រះរាជសារ នេះ និងញត្តិរំលឹកព្រឹត្តិការណ៍ប្រវត្តិសាស្រ្តក្នុងឆ្នាំ ១៨៩៧ បង្កឱ្យមានផលវិបាកនៅក្នុងច្បាប់សាធារណៈអន្តរជាតិ ។ ប្រការនេះបង្ហាញថា មហាក្សត្រិយ និងប្រជារាស្រ្តហាវ៉ៃ មិនដែល ព្រមចុះចាញ់ដោយគ្មានលក្ខខណ្ឌចំពោះរដ្ឋាភិបាលបន្ទាប់ដែលដឹកនាំប្រទេសនេះឡើយ ៖ ដោយហេតុនេះ រដ្ឋាភិបាលបន្ទាប់ដែលឡើងកាន់អំណាចនៅប្រទេសហាវ៉ៃ គឺជារដ្ឋាភិបាលក្រៅផ្លូវការតែប៉ុណ្ណោះ ។ រាជរដ្ឋាភិបាលហាវ៉ៃស្របច្បាប់រក្សានូវស្ថានភាពរបស់ខ្លួនជា រាជរដ្ឋាភិបាលស្របច្បាប់ជារៀងរហូត។ ព្រះរាជសាររបស់មហាក្សត្រិយមានអត្ថន័យដូចតទៅនេះ ៖

យើង មហាក្សត្រិយ Liliuokalani ដោយ ព្រះគុណនៃព្រះជាម្ចាស់ និងស្ថិតក្រោមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រហាវ៉ៃ ធ្វើការតវ៉ាយ៉ាងមុតមាំប្រឆាំងនឹងអំពើណាមួយ និងសកម្មភាពទាំងអស់ ដែលបានប្រព្រឹត្តឡើងប្រឆាំងនឹងខ្លួនយើង និងរាជរដ្ឋាភិបាលស្របតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រហាវ៉ៃ ដោយបុគ្គលមួយចំនួន ដែលអះអាងថាបង្កើតរដ្ឋាភិបាល បណ្តោះអាសន្ននៃ និងសម្រាប់ព្រះរាជាណាចក្រនេះ។

ការណ៍ដែលយើងប្រគល់ការគ្រប់គ្រងប្រទេសទៅឱ្យកងកម្លាំងសហរដ្ឋអាមេរិកដ៏ឧត្តមដែលមានរដ្ឋមន្រ្តីពេញសមត្ថភាព ឯកឧត្តម John L. Stevens បានបណ្តាលឱ្យកងទ័ពសហរដ្ឋអាមេរិក បោះទីតាំងនៅរាជធានី Honolulu ហើយបានប្រកាសថា លោកនឹងគាំទ្ររដ្ឋាភិបាលបណ្តោះអាសន្ន ។ ឥឡូវនេះ ដើម្បីចៀសវាងការប៉ះទង្គិចគ្នាដោយកងកម្លាំងប្រដាប់អាវុធ ហើយដែលប្រហែលជាអាចធ្វើឱ្យមានការបាត់បង់អាយុជីវិតមនុស្ស <u>យើងធ្វើបែបនេះដោយបិតនៅក្រោមគំនាបតវ៉ា</u> និងការបង្ខំដោយកងកម្លាំងដ៏ឧត្តមនេះ ហើយក៏ព្រមប្រគល់អំណាចរបស់យើង រហូតដល់ពេលវេលាមួយ ដែលរដ្ឋាភិបាលសហរដ្ឋអាមេរិក ដោយផ្អែកលើការពិតដូចបានលើកឡើងក្នុងព្រះរាជសារនេះ ដកតំណាងរបស់ខ្លួនចេញ ហើយ

ប្រគល់អំណាចមកឱ្យយើងគ្រប់គ្រងវិញ តាមការទាមទាររបស់យើងថាជារាជាណាចក្រអាស្រ័យរដ្ឋធម្មនុញ្ញពេញទៅដោយអធិបតេយ្យភាពនៃកោះហាវ៉ៃ។

ធ្វើនៅ Honolulu ថ្ងៃទី១៧ ខែមករា ឆ្នាំ១៨៩៣ ។